# ព្រឹម ជិនៈ ការលួច និង ការបំផ្លាញប្រាសាទកោះកេរ ដោយបារាំង

***(សំណេរៈ ចាន់ ប្រាថ្នា, ពិនិត្យៈ ឆាំង យុ)***

ក្នុងនាមជាប្រជាជនខ្មែរម្នាក់ ព្រឹម ជិន ទទួចសុំឲ្យបារាំងប្រគល់សងកម្ពុជាវិញនូវវត្ថុបុរាណ ដែលបារាំងបានយកយ៉ាងច្រើនសន្ធឹកសន្ធាប់ចេញពីប្រាសាទកោះកេរ ក្នុងអំឡុងទសវត្សន៍ឆ្នាំ៥០ ។ ព្រឹម ជិន មានស្រុកកំណើតនៅភូមិកោះកេរ ឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តព្រះវិហារ (ពីដើមខេត្តសៀមរាប) ។ បច្ចុប្បន្ន ព្រឹម ជិន ស៊ីឈ្នួលយាមប្រាសាទកេះកេរ និង កត់ត្រាចំនួនភ្ញៀវបរទេសដែលមកមើលប្រាសាទ ឲ្យអាជ្ញាធរអបសរា ។ ព្រឹម ជិន ជាអ្នកបានឃើញជនជាតិបារាំងដឹករូបចម្លាក់យ៉ាងច្រើនសន្ធឹកសន្ធាប់យកចេញពីប្រាសាទកោះកេរ និងជាសាក្សីប្រវត្តិសាស្រ្តសម្រាប់កូនខ្មែរជំនាន់ក្រោយ ។

ក្នុងវ័យ ៧០ឆ្នាំ ព្រឹម ជិន ទំនងជាមានភាពហត់នឿយក្នុងការរត់ចុះរត់ឡើងៗ ដោយគ្មានស្បែកជើង និងទៅមុខទៅក្រោយៗប្រាសាទ ដើម្បីតាមមើលភ្ញៀវទេសចរ ។ ទោះបីជាយ៉ាងនេះក្តី ព្រឹម ជិន នៅតែមានទឹកមុខញញឹមក្នុងការឆ្លើយប្រាប់គ្រប់យ៉ាង *“ចុះយើងលាក់ធ្វើអីជាតិខ្មែរយើង”* នៅពេលសួរគាត់អំពីការលួច និងការបំផ្លិចបំផ្លាញរូបចម្លាក់នៅប្រាសាទកោះកេរ ។ ព្រឹម ជិន និយាយរៀបរាប់អំពីការលួចរូបចម្លាក់ ដែលដាក់នៅតាមកំពែងជុំវិញប្រាសាទក្រហមក្នុងបរិវេណប្រាសាទកោះកេរ និងការជីកកកាយប្រាសាទកោះកេរ(ប្រាសាទធំ) ដោយជនជាតិបារាំង ។

## ១) បារាំងដឹកយករូបចម្លាក់យ៉ាងតិច ១០០រូប ចេញពីប្រាសាទកោះកេរ

ព្រឹម ជិន បញ្ជាក់ថា បារាំងបានប្រមូលយករូបចម្លាក់ខ្មែរយ៉ាងតិចចំនួន ១០០ ចេញពីប្រាសាទកោះកេរ ។ ក្នុងនោះមានរូបៈ ខ្លួនមនុស្សក្បាលគោ ខ្លួនមនុស្សក្បាលសេក ខ្លួនមនុស្សក្បាលសេះ ខ្លួនមនុស្សក្បាលឆ្កែ ខ្លួនមនុស្សក្បាលយក្ស ខ្លួនមនុស្សក្បាលស្វា ខ្លួនមនុស្សក្បាលអណ្តើក ខ្លួនមនុស្សក្បាលដំរី ។ រូបទាំងនោះមានទំហំធំៗ និងមានកម្ពស់ពី ០,៨ម៉ែត្រ ទៅ ១ម៉ែត្រ ។ រូបខ្លះមានកម្ពស់ជិត ២ម៉ែត្រ បើគិតទាំងជើងទម្រ(បល្ល័ង្គ) ។ រហូតមកដល់ពេលនេះ រូបទាំងនោះពុំទាន់ត្រូវបានបញ្ជូនមកប្រាសាទកោះកេរនូវឡើយ ។

កាលពីក្មេង ព្រឹម ជិន ធ្លាប់ស៊ីឈ្នួលជុសលាងសម្អាតរូបចម្លាក់នៅប្រាសាទកោះកេរ ឲ្យជនជាតិបារាំង ដោយទទួលបានប្រាក់កម្រៃ ១រៀល (លុយខ្មែរ) សម្រាប់ការជុសលាងរូបចម្លាក់១ ។ ពេលនោះ ព្រឹម ជិន មានអាយុប្រហែល ១១ឆ្នាំ ហើយឪពុករបស់គាត់ជាជំនួយការរបស់ជនជាតិបារាំងទាំងនោះ ។ ឪពុករបស់ ព្រឹម ជិន ឈ្មោះ ព្រឹម ចេះនិយាយភាសាបារាំងយ៉ាងស្ទាត់ជំនាញ ។ ព្រឹម ជិន រៀបរាប់ថា ពេល


66 Preah Sihanouk Blvd. ◆ P.O.Box 1110 ◆ Phnom Penh ◆ Cambodia
t (855-23) 211-875 ◆ f (855-23) 210-358 ◆ dccam@online.com.kh ◆ www.dccam.org

ចាន ប្រាថ្នា៖ ថ្ងៃទី ២១ ខែសីហា ឆ្នាំ២០១៤

បារាំងមកដល់ភូមិកោះកេរភ្លាម បារាំងបានបង្គាប់ឲ្យប្រធានភូមិឈ្មោះ ភូម មែន ហៅប្រជាជននៅក្នុងភូមិឲ្យមកជួបជុំគ្នា ដើម្បីជួលឲ្យជុសលាងសម្អាតរូបចម្លាក់នៅប្រាសាទកោះកេរ ។ ពេលប្រជុំ ភូម មែន ប្រាប់ប្រជាជនថា បារាំងជួលឲ្យជុសលាងសម្អាតរូបចម្លាក់នៅប្រាសាទកោះកេរ ដោយផ្ដល់ប្រាក់កម្រៃ "*លាងសម្អាតរូបចម្លាក់បាន ១ ទទួលបាន ១រៀល លាងបានរូប១០ ទទួលបាន ១០រៀល*" ពោលគឺអាស្រ័យទៅតាមចំនួនរូបដែលដុះសម្អាតបាន ។ បន្ទាប់ពីឮដូច្នេះ ប្រជាជនមួយចំនួននៅក្នុងភូមិកោះកេរ មានទាំងក្មេងៗ និងមនុស្សចាស់ នាំគ្នាស៊ីឈ្នួលជុសសម្អាតរូបចម្លាក់ឲ្យជនជាតិបារាំងទាំងនោះ ។

ព្រឹម ជិន បញ្ជាក់ថា គាត់ទទួលបានច្រាស១ ធុងទឹក១ និងក្រណាត់១ សម្រាប់ជុសលាងសម្អាតរូបចម្លាក់ ។ អ្នកផ្សេងៗទៀត ក៏ទទួលបានដូចគ្នា ។ ក្នុងមួយថ្ងៃ គាត់អាចលាងសម្អាតរូបចម្លាក់បានពី ១០ ទៅ ២០រូប ពោលគឺអាស្រ័យលើកម្រាស់ស្លែ ដែលនៅជាប់រូបទាំងនោះ ។ ព្រឹម ជិន ជុសលាងរូបចម្លាក់ សរុបទាំងអស់បានចំនួន ២៥រូប ដោយទទួលបានប្រាក់កម្រៃ ២៥ រៀល ។ គាត់ប៉ាន់ប្រមាណថា រូបចម្លាក់ដែលបារាំងជួលប្រជាជនឲ្យជុសសម្អាត ទាំងអស់មានចំនួនច្រើនជាង ១០០ ហើយសុទ្ធសឹងតែជារូបចម្លាក់ល្អៗ ។ ឪពុករបស់គាត់ ជាអ្នកដើរត្រួតពិនិត្យមើលការជុសសម្អាតនេះដោយផ្ទាល់ ។ រូបទាំងនោះមានទីតាំងនៅតាមកំពែងព័ទ្ធជុំវិញប្រាសាទក្រហម និង នៅក្នុងប្រាសាទផ្សេងៗទៀតក្នុងបរិវេណប្រាសាទកោះកេរ ។



ព្រឹម ជិន បង្ហាញទីតាំងរូបចម្លាក់ដែលគាត់បានជុសសម្អាត ។ នេះជាកំពែង (ទី១) សង់ព័ទ្ធជុំវិញប្រាសាទក្រហម ។ នៅចន្លោះនេះ មានរូបចម្លាក់១ជួរ មានកម្ពស់ជិតស្មើកំពែង ។ (រូបថត៖ ប្រាថ្នា)



ព្រឹម ជិន ចង្អុលបង្ហាញទីតាំងរូបចម្លាក់ ៣ជួរផ្សេងទៀត នៅចន្លោះ កំពែងទី២ នៃប្រាសាទក្រហម ។ ព្រឹម ជិន បញ្ជាក់ថា រូបចម្លាក់ទាំង អស់មានចំនួន៨ជួរ ។ (រូបថត៖ ប្រាថ្នា)

បារាំងយករូបទាំងអស់នោះចេញពីប្រាសាទកោះកេរ ។ ព្រឹម ជិន បញ្ជាក់ថា បន្ទាប់ពីជុសលាងរួច បារាំងបាននាំគ្នាដឹកជញ្ជូនរូបចម្លាក់ទាំងនោះទាំងថ្ងៃទាំងយប់ យកចេញពីប្រាសាទកោះកេរ ។ នៅពេលសួរថា តើគេ (បារាំង) មានប្រាប់ថា គេយករូបនឹងទៅទីណាទេ? ព្រឹម ជិន ឆ្លើយថា "*អត់ទេ! អត់មានប្រាប់ទេ ។ អត់មានប្រាប់មានអីទេ ។ មកដកយកទៅខ្លួនវា ។ ស្រេចតែចិត្តវា ។ អត់មានប្រាប់ពីណាទេ* " ។ នៅពេលសួរទៀតថា ចុះពេលឃើញបារាំងយកនៅនឹងភ្នែកអញ្ចឹង ប្រជាជនអត់មានថាយ៉ាងម៉េចទេ? ព្រឹម ជិន បញ្ជាក់ថា "*ចុះថាអី! មានអំណាចអីនឹងថា ។ សូម្បីប្រធានភូមិមិនហ៊ានថាផង ។ អត់ហានថាទេ ព្រោះគេកាន់នៅប្រទេសខ្មែរយើងហើយដែលហ៊ានថាគេ ។ អត់ហ៊ានទេ! មេភូមិក៏មិនហ៊ាន មេឃុំក៏មិនហ៊ាន*" ។

បារាំងបានប្រើ កៅឡាក់ និង ឡានស្ទូច ដើម្បីលើក និងដឹកជញ្ជូនរូបចម្លាក់យកចេញពីប្រាសាទកោះកេរ ។ ព្រឹម ជិន រៀបរាប់ថា បារាំងបានជួលប្រជាជនឲ្យជីកលកដីនៅក្រោមរូបចម្លាក់ទាំងនោះ ដើម្បីសឹកខ្សែចង ។ បន្ទាប់មក បារាំងប្រើកៅឡាក់ដើម្បីរំកិលរូបទាំងនោះចេញពីទីតាំងដើម ហើយប្រើឡានស្ទូចរូបទាំងនោះដាក់ក្នុងឡានដឹកយកចេញទៅ ។ ព្រឹម ជិន បញ្ជាក់ថា ឡាននោះដាក់រូបចម្លាក់បានចំនួន ១៥រូប ដោយតម្រៀបជា ៣ជួរ ដែលក្នុងមួយជួរៗ មានរូបចម្លាក់ចំនួន ៥ ។

### ២) បារាំងគាស់យករូបសំណាកលិង្គព្រះឥសូរ និងយោនីនាងឧមា ពីប្រាសាទកោះកេរ

បច្ចុប្បន្ន នៅលើកំពូលប្រាសាទកោះកេរ (ប្រាសាទធំ) នៅសល់តែបំណែកថ្មបាក់បែក និងប្រហោងធំមួយ (បួនជ្រុង និងជ្រៅចុះទៅក្រោម) នៅចំពាក់កណ្ដាលប្រាសាទតែប៉ុណ្ណោះ ។ បារាំងជាអ្នកគាស់បំផ្លាញប្រាសាទនេះ ។ ព្រឹម ជិន បញ្ជាក់ថា កាលពីមុនកំពូលប្រាសាទនេះពុំសូវមានការបែកបាក់ខ្លាំងនោះទេ ហើយប្រហោងធំនេះ ភ្ជិតដោយរូបសំណាក យោនីនាងឧមា និង លិង្គព្រះឥសូរ ។ លិង្គនេះមានកម្ពស់ប្រហែល ៤ម៉ែត្រ និង ទំហំជាង ១ម៉ែត្រ ។ ព្រឹម ជិន អះអាងថា រូបគាត់ និងឪពុក បានឃើញដោយផ្ទាល់នៅពេលបារាំងគាស់យករូបសំណាកទាំងពីរនេះ ។ បារាំងប្រើយន្តហោះ (អេឡេកុបទ័រ) ស្ទូចរូបសំណាកនេះដាក់ក្នុងឡាន រួចដឹកយកចេញពីប្រាសាទកោះកេរ ។

ចប់